ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១១ សសរ

សេចក្តីសម្រេច

ស្តីពី

ការរៀបចំកិច្ចប្រជុំនៃក្រុមពិគ្រោះយោបល់លើកទី៧

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស/ ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ. បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យរបស់រាជរដ្ឋាភិបាល លេខ ៧០ អនក្រ.បក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- តាមសំណើរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានទី ១ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

# សម្រេច

ប្រការ ១ : ប្រគល់ភារកិច្ចជូនឯកឧត្តម គាត ឈន់ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានទី១នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងការដឹកនាំនិងសំរបសំរួលការងារត្រៀមរៀបចំ សំរាប់កិច្ចប្រជុំនៃក្រុមពិគ្រោះយោបល់លើកទី ៧ ដែលនឹងប្រព្រឹត្តទៅក្នុងឆ្នាំ ២០០៤ នេះ ។

**ប្រការ ២** : ក្នុងក្របខ័ណ្ឌនៃការដឹកនាំនិងសំរបសំរួលការងារត្រៀមរៀបចំសំរាប់កិច្ចប្រជុំនេះ ឯកឧត្តម **គាត ឈន់** ត្រូវសហការជាមួយប្រធាននៃបណ្ដាក្រសួងនិងស្ថាប័នទាំងអស់របស់រាជរដ្ឋាភិបាល និងមានសិទ្ធិអញ្ជើញមន្ត្រីជាន់ខ្ពស់អោយចូលរួមប្រជុំអន្តរក្រសួង និងមានសិទ្ធិចាត់ចែងពិគ្រោះយោបល់ជាមួយតំណាងប្រទេសនិងអង្គការអន្តរជាតិអ្នកផ្ដល់ជំនួយទ្វេភាគី និងពហុភាគី ដើម្បីសំរបសំរួលការងារ និងដើម្បីរៀបចំសេចក្ដីព្រាងឯកសារចាំបាច់ៗនានា ។

**ប្រការ ៣** : ឯកឧត្តម **គាត ឈន់** ត្រូវរាយការណ៍ជាបន្តបន្ទាប់ជូនសម្ដេចនាយករដ្ឋមន្ត្រី អំពីវឌ្ឍនភាពនៃការរៀបចំ ហើយត្រូវរៀបចំឯកសារចាំបាច់នានាសំរាប់កិច្ចប្រជុំលើកទី ៧ នេះ ដើម្បីដាក់ជូនសម្ដេចនាយករដ្ឋមន្ត្រីពិនិត្យ ផ្ដល់យោបល់ណែនាំ និងអនុម័ត មុននឹងយកទៅប្រើប្រាស់ជាផ្លូវការ ។

**ប្រការ ៤** :ក្នុងការបំពេញកិច្ចការនេះ ឯកឧត្តម **គាត ឈន់** ប្រើប្រាស់រចនាសម្ព័ន្ធរបស់គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា (គអក/គជនា) ដែលមានឯកឧត្តម **ឈៀវ យ៉ាណារ៉ា** ជាអគ្គលេខាធិការ សំរាប់ជំនួយការងារប្រចាំថ្ងៃ ។

**ប្រការ ៥** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួងនិងស្ថាប័នពាក់ព័ន្ធ និងឯកឧត្តម **គាត ឈន់** ត្រូវអនុវត្តតាមសេចក្ដីសំរេចនេះ អោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ ៦** : សេចក្ដីសំរេចនេះអោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខារហូតដល់កិច្ចប្រជុំលើកទី៧នៃក្រុមពិគ្រោះយោបល់បានប្រព្រឹត្តទៅចប់សព្វគ្រប់ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មិនា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ដូចប្រការ៥ " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ